# អំពីគម្រោង

Chinatown គឺជាមជ្ឈមណ្ឌលដ៏សំខាន់មួយសម្រាប់ជីវិត និងវប្បធម៌របស់ប្រជាជនអាស៊ីនៅក្នុងទីក្រុង ហ្វីឡាដែលហ្វ្យ៉ា។ ប៉ុន្មានឆ្នាំកន្លងមកនេះ ការកម្សាន្ត លំនៅដ្ឋាន និងតម្រូវការខាងសេវាកម្មសង្គមមានការរីកចម្រើនអភិវឌ្ឍជាងមុន។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ Chinatown ប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា (Philadelphia Chinatown Development Cooperation) បានធ្វើការជាមួយនឹងសហគមន៍ដើម្បីបង្កើតផែនការប្រកបដោយមហិច្ឆតាសម្រាប់មជ្ឈមណ្ឌលសហគមន៍ចម្រុះក្នុងគោលបំណងដោះស្រាយ តម្រូវការទាំងនោះ។

- អគារ Crane Chinatown ដែលមានទីតាំងស្ថិតនៅផ្លូវលេខ 10 និង Vine គឺជាមជ្ឈមណ្ឌលប្រើប្រាស់ចម្រុះមួយដែលផ្តល់៖
- កម្មវិធីសម្រាប់គ្រួសារ
- កម្មវិធីសម្រាប់យុវវ័យ និងមនុស្សចាស់
- សេវាកម្មខាងវិស័យអប់រំ និងសុខភាព
- ព្រឹត្តិការណ៍សង្គម ការកម្សាន្ត និងវប្បធម៌
- លំនៅដ្ឋាន
- ទីតាំងអាជីវកម្ម

អគារបានធ្វើឱ្យគុណភាពនៃបរិស្ថានជុំវិញមានភាពប្រសើរឡើង ហើយនឹងជួយសហគមន៍ Chinatown ពង្រីកភាគខាងជើងនៃផ្លូវ Vine។
អគារនឹងផ្តល់លំនៅដ្ឋានមានគុណភាពសម្រាប់និវត្តជនដែលកំពុងស្វែងរកកន្លែងសម្រាប់មនុស្សចាស់
ជនអន្តោប្រវេសន៍ថ្មីដែលកំពុងស្វែងរកកន្លែងដើម្បីតាំងលំនៅដ្ឋាន
ព្រមទាំងអ្នកជំនាញដែលធ្វើការនៅ Center City ទាំងអស់។

បន្ទាប់ពីធ្វើផែនការអស់ជាច្រើនទសវត្ស អគារ Crane បានក្លាយជាសមិទ្ធផលដ៏សំខាន់មួយ ទោះបីជាទទួលរងសម្ពាធពីការអភិវឌ្ឍឡើងវិញ និងការធ្វើវិមាត្រភាពនៃសង្កាត់ថ្មីក៏ដោយ។ Crane Chinatown គឺជាបេះដូងថ្មីរបស់សហគមន៍ ដែលជានិមិត្តរូបតំណាងឱ្យភាពរឹងមាំ និងក្លៀវក្លា។

គេហទំព័រនេះគឺជាការងារដែលកំពុងដំណើរការ។ យើងនឹងបញ្ចូលព័ត៌មានបន្ថែមទៀតនៅពេលដែលគម្រោងមានការអភិវឌ្ឍទៅមុខ។

承前启后 继往开来

## សិល្បៈសាធារណៈនៅអគារ Crane *អតីតកាលគាំទ្រអនាគត*

ដើម្បីធ្វើការកត់សម្គាល់ពីសារៈសំខាន់នៃអគារ Crane កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ Chinatown ប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា (Philadelphia Chinatown Development Corporation) សិល្បៈគំនូរប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា (Mural Arts Philadelphia) និង PHDC បានធ្វើការស្នើសុំឱ្យសិល្បករអាស៊ីចំនួនបួននាក់បង្កើតផ្ទាំងគំនូរនៅផ្នែកខាងក្នុង និងខាងក្រៅអាគារថ្មី។ ប្រធានបទនៃសិល្បៈគឺ "អតីតកាលគាំទ្រអនាគត"។

សិល្បករមានភាពរំភើបរីករាយក្នុងការជជែកជាមួយមនុស្សដែលមានទំនាក់ទំនងជាមួយនឹងសហគមន៍ Chinatown។ ចែករំលែកប្រវត្តិ និងគំនិតរឿងរ៉ាវ និងបទពិសោធន៍របស់អ្នក។
អ្នកនឹងជួយយើងឱ្យទទួលបានគំនិតថ្មីៗសម្រាប់ការងារសិល្បៈ។
នៅក្នុងដំណើរការក្រោយមកទៀត អ្នកនឹងមានឱកាស ក្នុងការជួយគូរផ្ទាំងគំនូរផ្នែកខាងក្រៅ។ ជនជាតិអាស៊ី-អាមេរិកាំងនៅទីក្រុងហ្វីឡាដែលហ្វ្យ៉ាទាំងអស់ និងជាពិសេស សហគមន៍ Chinatown ត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងការសន្ទនានេះផងដែរ។

ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ
សិល្បករនឹងអញ្ជើញសាធារណជនឱ្យចូលរួមក្នុង៖
- វគ្គបំផុសគំនិត
- សិក្ខាសាលាបង្រៀនអំពីរបៀបនៃការថតវីដេអូជាមួយគ្រួសារ និងមិត្តភក្តិ
- សិក្ខាសាលាគំនូរ

ដោយសារតែជម្ងឺកូវីដ-១៩ យើងនឹងធ្វើការរៀបចំសិក្ខាសាលា និងការសម្ភាសន៍ភាគច្រើនតាមប្រព័ន្ធ អ៊ីនធឺណិត។
យើងនឹងប្រើប្រាស់កម្មវិធី Zoom, WeChat, Facebook, Instagram, FaceTime និងវេទិកាផ្សេងៗទៀត។

បញ្ហាមួយចំនួនដែលយើងសង្ឃឹមថានឹងលើកយកមកពិភាក្សា៖
- ប្រវត្តិសាស្ត្ររបស់ Chinatown
- បទពិសោធន៍របស់ជនជាតិអាស៊ី-អាមេរិកាំងនៅក្នុងសហរដ្ឋអាមេរិក និងទីក្រុងហ្វីឡាដែលហ្វ្យ៉ា
- បទពិសោធន៍របស់ជនអន្តោប្រវេសន៍ដែលមករស់នៅសហរដ្ឋអាមេរិក
- បទពិសោធន៍របស់ជនជាតិអាមេរិកដើមកំណើតអាស៊ីអាមេរិកាំង
- ក្តីសង្ឃឹមសម្រាប់អនាគត
- ទំនាក់ទំនងជាមួយប្រទេសកំណើត
- តើវាមានន័យយ៉ាងដូចម្តេចដែលមានទីតាំងប្រវត្តិសាស្ត្រដូចជា Chinatown នៅក្នុងទីក្រុង ហ្វីឡាដែលហ្វ្យ៉ា ហើយទំនាក់ទំនងរបស់វាជាមួយនឹងតំបន់អាស៊ី-អាមេរិកាំងនាពេលថ្មីៗនេះ (ឧទាហរណ៍ - សហគមន៍វៀតណាមនៅទីក្រុងហ្វីឡាដែលហ្វ្យ៉ាខាងត្បូង)

តើអ្នកចង់ក្លាយជាផ្នែកមួយនៃគម្រោងដ៏សំខាន់នេះឬទេ?
សូមទំនាក់ទំនងមកកាន់ក្រុមការងារសិល្បៈគំនូរប្រចាំទីក្រុងហ្វីឡាដែលហ្វ្យ៉ា (Chinatown Crane Mural Team) តាមរយៈអាសយដ្ឋានអ៊ីម៉ែល chinatowncranemural@gmail.com ។

ដើម្បីថ្លែងអំណរគុណចំពោះការចូលរួមរបស់អ្នក
យើងនឹងផ្តល់អំណោយជាវិញ្ញាបនប័ត្រដល់អ្នកចូលរួមគម្រោងទាំងអស់ ដែលបានមកពីអ្នកគ្រប់គ្រងអាជីវកម្មជនជាតិអាស៊ីប្រចាំ Chinatown (ដរាបណា ការផ្គត់ផ្គង់នៅតែមាន)។

This project is being supported by Mural Arts Philadelphia, the Philadelphia Chinatown Development Corporation, and the Philadelphia Redevelopment Authority's Percent for Art Program.